ធ៥-៩៨-៤៤៣ ប្រក

# ប្រកាស

# ស្តីពី

# ការកំណត់អត្រាការប្រាក់បញ្ញើ សំរាប់សាខាធនាគារជាតិខេត្ត-ក្រុងអនុវត្តជាមួយអតិថិជន

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំ រេ ច

**ប្រការ ១** : កំណត់អត្រាការប្រាក់ចំនួន ១% ( មួយភាគរយ) ក្នុងមួយខែ សំរាប់ប្រាក់បញ្ញើជារៀលមាន កំណត់កាល ៣ ខែ ដែលអតិថិជនយកមកផ្ញើនៅតាមសាខាធនាគារជាតិខេត្ត-ក្រុង ក្នុងព្រះរាជា- ណាចក្រកម្ពុជា ។

**ប្រការ ២** : រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណាមានខ្លឹមសារផ្ទុយពីស្មារតីប្រកាសនេះមានជាអាទិ៍ ប្រកាសលេខធ៥.៩៦-0៧ ប្រក ស្តីពីការកំណត់ការប្រាក់បញ្ញើ និងអោយខ្ចីចងការសំរាប់ធនាគារ ខេត្ត-ក្រុងអនុវត្តជាមួយអតិថិជន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣** : អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាននិងគ្រប់នាយកដ្ឋាន-អង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាខាធនាគារជាតិខេត្ត-ក្រុង សាមីនីមួយៗត្រូវអនុវត្ត ម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា **ជា ចាន់តូ**